ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការខេត្តបាត់ដំបង
សំណុំរឿងព្រហ្មទណ្ឌ
លេខ : ៩២៨ ចុះថ្ងៃទី ១៤
ខែ វិច្ឆិកា ឆ្នាំ ២០០៥
សាលក្រមព្រហ្មទណ្ឌ
លេខ : ៣១ "ក" ចុះថ្ងៃទី ១០
ខែ កុម្ភៈ ឆ្នាំ ២០០៦

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការខេត្តបាត់ដំបង**

បានបើកសវនាការជាសាធារណៈនៅនាទីតុលាការខេត្តបាត់ដំបង នៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០០៦ ដោយមានសមាសភាពដូចតទៅ :

**ចៅក្រមជំនុំជំរះ**

លោក [redacted] ជាប្រធានតុលាការខេត្តបាត់ដំបង

**តំណាងអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញារងអមតុលាការខេត្តបាត់ដំបង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

**ដើម្បីជំនុំជំរះ**

រឿងក្តីព្រហ្មទណ្ឌលេខ ៩២៨ ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ដែលមានជនជាប់ចោទ ។

១-ឈ្មោះ **ស មនរ** ហៅ **ខ** ភេទប្រុស អាយុ ១៦ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ មានរបររកស៊ីកម្មករ មានទីកន្លែងកំណើតនៅភូមិព្រៃរំយក់ ឃុំព្រៃរំយក់ ស្រុកបរិតខេត្តស្វាយរៀង មានកំរិតវប្បធម៌ថ្នាក់ទី ៦ថ្មី កាន់សាសនាព្រះពុទ្ធ មានទីលំនៅសព្វថ្ងៃនៅភូមិជ្រៃកោង ឃុំស្លាកែត ស្រុកបាត់ដំបង ខេត្តបាត់ដំបង នៅលីវ មានឪពុកឈ្មោះ **ស សល** (ស) ម្តាយឈ្មោះ **ជ សត** (រ) ទោសពីមុនគ្មាន ។ ត្រូវចាប់ខ្លួនកាលពីថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៥ នៅចំណុចភូមិជ្រៃកោង ឃុំស្លាកែត ស្រុកបាត់ដំបង ខេត្តបាត់ដំបង ហើយត្រូវបានឃុំខ្លួនតាមដីកាលេខ ៥៧១ ដ.ឃ.ខ ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៥ នៅអាគារឃុំខ្លួន នៃពន្ធនាគារខេត្តបាត់ដំបង ។

ត្រូវចោទពីបទ **ប្លន់** តាមបញ្ញត្តិមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោស នៃបទឧក្រិដ្ឋ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០១០២/០០៤ ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០២ ប្រព្រឹត្តនៅភូមិជ្រៃកោង ឃុំស្លាកែត ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ។ ដោយមានលោក **ឈុច ចំនួសុខា** ជាមេធាវីការពារជនជាប់ចោទ ។

ជនរងគ្រោះឈ្មោះ **ឆ ឆ** ហៅ **ត** ភេទប្រុស អាយុ ៣៣ឆ្នាំ ជាតិខ្មែរ របររកស៊ីលក់ដូរ ទីលំនៅភូមិ ជ្រៃកោង ឃុំស្លាកែត ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

**ការប្រព្រឹត្តិរបស់ជនជាប់ចោទមានដូចតទៅ :**

នៅថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ឈ្មោះ **ស មនរ** និង ឈ្មោះ **ខ** បានជិះ



Scanned with CamScanner

ម៉ូតូដើរលេង ពេលមកដល់ភូមិជ្រៃកោង ក៏ឃើញតូបគេបិទទ្វារ ក៏ឈ្មោះ មនរ ចូលលួច [illegible] ព្រោះ
ពេលលួចសាំងបានម្តង ហើយក៏មកលួចម្តងទៀត ក៏ត្រូវម្ចាស់គេទាន់ដេញចាប់តែម្តង ឯឈ្មោះ ខ បានរត់គេចខ្លួនបាត់ ។

តាមរបាយការណ៍លេខ ១៥៨ នប.ស.ប ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៥ របស់ប៉ុស្តិ៍នគរបាលឃុំស្លាកែត បានបញ្ជាក់ថា នៅថ្ងៃទី ០៩ និងទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៥ នៅចំណុចភូមិជ្រៃកោង មានករណីចោរកម្មមួយកើតឡើងបង្កដោយជនល្មើសមានគ្នា ០២នាក់ បាននាំគ្នាចូលលួចយកសាំងនៅក្នុងផ្ទះឈ្មោះ ឆ ឆ បានសាំង ១២ដប ស្មើ ២៥លីត្រ ។

## នៅចំពោះមុខនាពេលសវនាការ

-ឈ្មោះ ស មនរ ជាជនជាប់ចោទបានឆ្លើយថា ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៥ វេលាម៉ោង ១១ជាងយប់ ខ្លួនពិតជាបានចូលលួចយកសាំងរបស់គេពិតប្រាកដមែន ។ ពេលធ្វើសកម្មភាពលួចនោះ ខ្លួនលួចម្នាក់ឯងទេ ឯឈ្មោះ ខ ចាំម៉ូតូខាងក្រៅ ។ ពេលចូលលួច ខ្លួនកាច់របងគេ និង បើកក្តារតូបគេចូលតែម្តង លួចយកសាំងចាក់ម៉ូតូខ្លះ និង លក់ខ្លះ ។

-តាមការអានចម្លើយឈ្មោះ ឆ ឆ ជាជនរងគ្រោះបានឆ្លើយថា : (មើលឯកសារលេខ ១៨) ។

-តាមការអានចម្លើយឈ្មោះ ម សរ ជាសាក្សីបានឆ្លើយថា : (មើលឯកសារលេខ ១៩) ។

## តំណាងអយ្យការបានធ្វើសន្និដ្ឋានថា

មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ស មនរ ពីបទ ប្លន់ នៅភូមិជ្រៃកោង ឃុំស្លាកែត កាលពីថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ។ ស្នើសុំតម្កល់បទចោទទុកជាបានការពេញទាំងមូល និង សុំឱ្យតុលាការផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ពី ០៥ ដល់ ០៧ឆ្នាំ ពីបទចោទ ។

## មេធាវីការពារជនជាប់ចោទធ្វើសន្និដ្ឋានថា :

-កូនក្តីខ្លួនត្រូវបានលោកព្រះរាជអាជ្ញាចោទប្រកាន់ពីបទប្លន់ តែកូនក្តីខ្លួនចូលលួចតែម្នាក់ឯងទេ ។

-សកម្មភាពកូនក្តីខ្លួនធ្វើ គឺតែម្នាក់ឯងទេ ពុំមានគូកននោះទេ ។

-ឆ្លងតាមការសួរដេញដោល កូនក្តីខ្លួនពុំបានប្រព្រឹត្តបទល្មើសប្លន់ទេ គឺជាបទល្មើសចោរកម្មប៉ុណ្ណោះ ។

-កូនក្តីខ្លួនជាអនីតិជន ជាបទល្មើសចោរកម្ម ហើយខាងអង្គការក៏បានការពារសិទ្ធិកុមារផងដែរ ដូចនេះសុំលោកចៅក្រមកែប្រែបទចោទ ពីបទប្លន់មកជាបទចោរកម្មវិញ តាមមាត្រា ៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-បានស្តាប់ចម្លើយដោះសាររបស់ជនជាប់ចោទ

-បានស្តាប់ក្រឡាបញ្ជីអានចម្លើយឱ្យការណ៍របស់ជនរងគ្រោះ និង សាក្សី

-បានស្តាប់ការសួរដេញដោលចោទឆ្លើយតទល់

-បានពិនិត្យកំណត់ហេតុ ឯកសារភស្តុតាងនានា

-បានស្តាប់សេចក្តីសន្និដ្ឋានចោទប្រកាន់ទោសរបស់តំណាងអយ្យការ

-បានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារជនជាប់ចោទ



Scanned with CamScanner

-បានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ
-បានពិចារណាត្រឹមត្រូវហើយ

## តុលាការខេត្តបាត់ដំបងយល់ឃើញថា

-ពិតជាកើតមានទូវអំពើប្លន់ "ចោរកម្មមានគ្នាច្រើននាក់" នៅភូមិជ្រៃកោង ឃុំស្ទាកែត ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ប្រាកដមែន ។
-អំពើចោរកម្មដែលកើតនៅទីកន្លែង និង ពេលវេលាដូចខាងលើពិតជាប្រព្រឹត្តឡើងដោយឈ្មោះ **ស មនះ** ហៅ **ខ** និង ឈ្មោះ **ខ** បានលបចូលលួចយកប្រេងសាំងរបស់ឈ្មោះ **ឆ ឆ** ដែលដាក់យមុខផ្ទះ យកទៅលក់ និង ប្រើប្រាស់ចាក់ម៉ូតូបំរើផលប្រយោជន៍សួនតួបុគ្គល និង បក្ខពួកបានសម្រេចប្រាកដមែន ដោយឈ្មោះ **ស មនះ** ជាចារី ឯឈ្មោះ **ខ** ជាជនសមគំនិតចាំមើលផ្លូវ និង ឌុបឈ្មោះ **មនះ** ដោយម៉ូតូ ។
-អំពើដែលឈ្មោះ **ស មនះ** បានប្រព្រឹត្តនៅទីកន្លែង និង ពេលដូចខាងលើនេះមានធាតុផ្សំគ្រប់គ្រាន់ជា បទប្លន់ "ចោរកម្មមានគ្នាច្រើននាក់" ដូចមានបញ្ញត្តិក្នុងមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោស នៃ បទឧក្រិដ្ឋ ។ ឈ្មោះ **ស មនះ** ជាសមត្ថជន គាត់មានអាយុ ១៦ឆ្នាំ មានស្មារតីជានាល្អ គាត់បាន លួចយកប្រេងសាំង របស់ឈ្មោះ **ឆ ឆ** ដែលបានទុកនៅយមុខផ្ទះដោយមានគូកន ០២នាក់ ឈ្មោះ **ខ** យកទៅចាត់ចែង លក់ និង ប្រើប្រាស់បំរើផលប្រយោជន៍សួនតួបុគ្គលខ្លួន និង បក្ខពួកបានសម្រេច ។

## យល់ឃើញថា

មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ **ស មនះ** ពីបទប្លន់ ប្រព្រឹត្តនៅទីកន្លែង និង ពេលវេលាដូច ការចោទប្រកាន់របស់ស្ថាប័នអយ្យការប្រាកដមែន ។

**ភស្តុតាងដាក់បន្ទុកមាន :**

-ចម្លើយដោះសាររបស់ជនជាប់ចោទបានឆ្លើយបញ្ជាក់យ៉ាងច្បាស់ពីអំពើដែលខ្លួនបានប្រព្រឹត្តថា ខ្លួន បានលួនចូលតាមរបងលបលួចយកប្រេងសាំងរបស់គេបាន ០២លីត្រ យកទៅចាក់ម៉ូតូ និង លក់យក ប្រាក់ចាយវាយ ដោយការលួចនោះខ្លួនជាអ្នកចូលលួចដោយផ្ទាល់ ឯឈ្មោះ **ខ** នៅចាំមើលផ្លូវខាងក្រៅ និង ចាំឌុបខ្លួន ពេលលក់បានចែកប្រាក់គ្នាក្នុងម្នាក់១បាន ១៥បាត ចម្លើយនេះវាស៊ីសង្វាក់គ្នាទៅនឹង ចម្លើយឱ្យការណ៍របស់ជនរងគ្រោះ និង សាក្សីឈ្មោះ **ម សទ** ។
-ចម្លើយឱ្យការណ៍របស់ជនរងគ្រោះឈ្មោះ **ឆ ឆ** បានឆ្លើយឱ្យការណ៍យ៉ាងច្បាស់លាស់ ហើយវាស៊ី សង្វាក់ទៅនឹងចម្លើយរបស់ជនជាប់ចោទ និង ចម្លើយសាក្សីឈ្មោះ **ម សទ** និង ហេតុការណ៍ កាលៈ ទេសៈ នៃបទល្មើស ។
-កំណត់ហេតុ ឯកសារភស្តុតាងនានាធ្វើដោយនគរបាលយុត្តិធម៌ ។

## យល់ឃើញថា

ឈ្មោះ **ស មនះ** នៅជាអនីតិជន គាត់មានជីវភាពក្រខ្សត់ គាត់ពុំដែលមានទោសពីមុនមក កម្មវត្ថុ នៃបទល្មើសមានតម្លៃទាប ជាហេតុអាចឱ្យតុលាការយកមកពិចារណាជាស្ថានសម្រាលទោសឱ្យគាត់បាន ។
ជនជាប់ចោទបានប្រព្រឹត្តបទល្មើសប្លន់ច្រើនលើកច្រើនសារ ជាហេតុតុលាការយកមកពិចារណាជាស្ថាន



Scanned with CamScanner

ទម្ងន់ទោសក្នុងការសំរេចពីទណ្ឌកម្ម ។

<u>**ហេតុដូច្នេះតុលាការវិនិច្ឆ័យសេចក្តី**</u>

១-ផ្តន្ទាទោស : ឈ្មោះ **ស មនះ** ហៅ ខ ដាក់ពន្ធនាគារកំណត់ ០២ឆ្នាំ និង ០៦ខែគត់ ដោយគិតចាប់ពីថ្ងៃឃុំខ្លួន ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ។ ពីបទ : ប្លន់ "ចោរកម្មមានគ្នាច្រើននាក់" ប្រព្រឹត្តនៅភូមិជ្រៃកោង ឃុំស្លាកែត ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ។ បទល្មើសព្រហ្មទណ្ឌ ទណ្ឌកម្ម និង ការផ្តន្ទាទោសមានបញ្ញត្តិក្នុងមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។ តាមបទបញ្ញត្តិមាត្រា ៦៨ ត្រង់វាក្យខណ្ឌ ២ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។ តាមបទបញ្ញត្តិមាត្រា ៤០ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារដែលមហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័ត នាថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៨៩ ។ តាមសេចក្តីណែនាំលេខ ០១-កយ.សណន/២០០៥ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៥ របស់ក្រសួងយុត្តិធម៌ ស្តីអំពីការអនុវត្តគោលការណ៍នានាក្នុងច្បាប់ជាតិ និង ច្បាប់អន្តរជាតិដែលកំពុងនៅជាធរមានទាក់ទងនឹងយុត្តិធម៌អនីតិជន ។

២-សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ **ស មនះ** ហៅ ខ ។ បើកផ្លូវប្តឹងឧទ្ធរណ៍កំណត់រយៈពេល ០២ខែ គិតចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមជំនុំជំរះ**

[redacted] [redacted]

---

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកអ្នកអនុវត្តច្បាប់សាលក្រម ឱ្យសំរេចតាមសាលក្រមនេះ និង ឱ្យអាជ្ញាធរគ្រប់ជាន់ថ្នាក់ជួយអនុវត្តច្បាប់ឱ្យបានសំរេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

*បាត់ដំបង. ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៦*

**ជ. ក្រឡាបញ្ជីសវនាការ**

[redacted]

**បានឃើញ**

*បាត់ដំបង. ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៦*

**ប្រធានតុលាការខេត្ត**

[redacted]

Scanned with CamScanner